# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:..១៧...សសរ.

# សេចក្តីសម្រេច
## ស្តីពីការបង្កើតគណ:កម្មាធិការសម្របសម្រួល កិច្ចការបញ្ជូន
## កងកម្លាំងចូលរួមបេសកកម្មរក្សាសន្តិភាព របស់អង្គការសហប្រជាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## <u>សម្រេច</u>

ប្រការ ១ : ត្រូវបានបង្កើតគណៈកម្មាធិការ សម្របសម្រួលកិច្ចការបញ្ជូនកងកម្លាំង ចូលរួមបេសកកម្មរក្សាសន្តិភាព របស់អង្គការសហប្រជាជាតិ ដែលមានសមាសភាព ដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១_ | ឯកឧត្តម ប្រាក់ សុខុន | រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| ២_ | ឯកឧត្តម ម៉ឹង សំផន | រដ្ឋលេខាធិការ ក្រសួងការពារជាតិ | អនុប្រធាន |
| ៣_ | ឯកឧត្តម អ៊ុច បូររិទ្ធ | រដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |
| ៤_ | ឯកឧត្តម អ៊ុក រ៉ាប៊ុន | រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៥_ | ឯកឧត្តម ជា តារា | នាយរងសេនាធិការចំរុះ នៃកងយោធពលខេមរភូមិន្ទ | សមាជិក |
| ៦_ | ឯកឧត្តម សំ ចណ្ណាថន | អគ្គលេខាធិការ អគ្គលេខាធិការដ្ឋាន ក្រសួងការពារជាតិ | សមាជិក |
| ៧_ | ឯកឧត្តម ស៊ុំ សំណាង | អគ្គនាយក អគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ ក្រសួងការពារជាតិ | សមាជិក |
| ៨_ | ឯកឧត្តម ចៅ តិរុណ | អគ្គនាយក អគ្គនាយកដ្ឋានសំភារៈ បច្ចេកទេស ក្រសួងការពារជាតិ | សមាជិក |

| | | | |
|---|---|---|---|
| ៩_ | ឯកឧត្តម មាស សាវ័ន | អគ្គនាយក អគ្គនាយកដ្ឋានយោធសេវា ក្រសួងការពារជាតិ | សមាជិក |
| ១០_ | ឯកឧត្តម ណាំម សុទត្ថិ | ទីប្រឹក្សា និងជានាយកខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ឡៅ ធាញ់ | សមាជិកអចិន្ត្រៃយ៍ |
| ១១_ | ឯកឧត្តម ខ្វាន់ ស៊ាម | មេបញ្ជាការ បញ្ជាការដ្ឋានកងវិស្វកម្ម អគ្គបញ្ជាការ | សមាជិក |
| ១២_ | ឯកឧត្តម ឆែម ពេត | ទីប្រឹក្សា និងជានាយកខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ញ៉ឹក ប៊ុនឆៃ | សមាជិក |
| ១៣_ | ឯកឧត្តម មាស សំអុល | នាយក នាយកដ្ឋានបុគ្គលិក ក្រសួងការពារជាតិ | សមាជិក |
| ១៤_ | ឯកឧត្តម សែម សុវណ្ណានី | អគ្គលេខាធិការរង អាជ្ញាធរជាតិកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន | សមាជិក ។ |

**ប្រការ ២** : គណៈកម្មាធិការនេះមានភារកិច្ច :

_សម្របសម្រួលកិច្ចការទាំងឡាយ ដែលមានការពាក់ព័ន្ធនឹងការត្រៀមរៀបចំកងកម្លាំង ទៅចូលរួមប្រតិបត្តិការរក្សាសន្តិភាព របស់អង្គការសហប្រជាជាតិ ជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ។

_តាមដានបូកសរុបរាយការណ៍ និងលើកយោបល់ជូនរាជរដ្ឋាភិបាលជ្រាបនិងសម្រេច រាល់កិច្ចការដែលមានការពាក់ព័ន្ធខាងលើនេះ ។

_ធ្វើកិច្ចការមួយចំនួនទៀត តាមការប្រគល់ភារកិច្ចពីរាជរដ្ឋាភិបាល ។

**ប្រការ ៣** : គណៈកម្មាធិការនេះ ត្រូវចូលរួមប្រជុំ តាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ ៤** : គណៈកម្មាធិការនេះ មានសិទ្ធិប្រើប្រាស់ត្រា របស់ទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីបំពេញកិច្ចការរបស់ខ្លួន ។

**ប្រការ ៥** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ឆ្នាំ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

_ក្រសួងព្រះបរមរាជវាំង
_អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
_អគ្គលេខាធិការដ្ឋានរដ្ឋសភា
_ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
_ ខុទ្ទកាល័យ សម្តេច និងឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
_ ដូចមាត្រា ៥
_ ឯកសារ_កាលប្បវត្តិ